# កម្មវិធីផ្សាយ និងប្រេកង់ (Broadcast Program and Frequencies)

## ការផ្សាយរបស់វិទ្យុអូស្ត្រាលីខេមរភាសា

វិទ្យុអូស្ត្រាលីខេមរភាសាធ្វើការផ្សាយ២ដងក្នុងមួយថ្ងៃ ហើយម្តងៗមានរយៈពេល៣០ នាទី។ កម្មវិធីផ្សាយទាំង២លើកនេះ ផ្សាយចេញតាមរយៈឧបករណ៍បញ្ជូនសម្លេង BBC Kranji នៅក្នុងប្រទេសសិង្ហបុរី។

កម្មវិធីផ្សាយរបស់យើងរួមមាន ព័ត៌មាន ព្រឹត្តិការណ៍បច្ចុប្បន្ន របាយការណ៍ឯកទេស អំពីកសិកម្មនិងបរិស្ថាន សង្គម សុខភាព វិទ្យាសាស្ត្រ ព្រឹត្តិការណ៍ក្នុងតំបន់ ការយល់ដឹងអំពីអូស្ត្រាលី នាទីភាគពិសេសៗ រួមទាំងកម្មវិធីរៀនភាសាអង់គ្លេសទៀតផង (English From Australia - EFA)។

## រលកអាកាសផ្សាយ

| រលកធាតុអាកាស | ម៉ោងនៅភ្នំពេញ (UTC + 7) |
|---|---|
| 9720 Khz (31 ម) | ០៦:00 - ០៦:៣០ (ព្រឹក) |
| 11920 Khz (25 ម) | ១២:00 - ១២:៣០ (ថ្ងៃត្រង់) |

## ការផ្សាយបន្តផ្ទាល់នៅកម្ពុជា

លោកអ្នកក៏អាចស្តាប់កម្មវិធីទាំងនេះនៅក្នុងស្រុកបានដែរតាមរយៈការផ្សាយបន្តផ្ទាល់នៅវិទ្យុមណ្ឌលព័ត៌មានស្ត្រីកម្ពុជា FM102 និងវិទ្យុឃ្លាំងមឿង FM90.25 វេលាម៉ោង១២ថ្ងៃត្រង់ដល់ម៉ោង១២កន្លះម៉ោងនៅកម្ពុជា។ វិទ្យុព្រហ្មមានជ័យ FM 96.5 នឹងចាប់ផ្តើមការផ្សាយបន្តផ្ទាល់នៅក្នុងពេលឆាប់ៗនេះ។

## ការចាប់សម្លេងតាមប្រព័ន្ធផ្កាយរណប

លោកអ្នកអាចនឹងចាប់វិទ្យុសញ្ញារបស់យើងតាមប្រព័ន្ធផ្កាយរណបផងដែរនៅក្នុងពេលឆាប់ៗនេះ៖

## កម្មវិធីផ្សាយថ្ងៃចន្ទដល់ថ្ងៃអាទិត្យ

| | |
|---|---|
| បើកកម្មវិធី ព័ត៌មាន និងព្រឹត្តិការណ៍បច្ចុប្បន្ន (ក្នុងនិងក្រៅប្រទេស) | 06:00 & ១២:00 |
| នាទីឯកទេស៖<br>• នាទីកសិកម្ម និងបរិស្ថាន (ថ្ងៃចន្ទ)<br>• នាទីកម្រងសង្គម (ថ្ងៃអង្គារ)<br>• នាទីសុខភាព (ថ្ងៃពុធ)<br>• នាទីវិទ្យាសាស្ត្រ (ថ្ងៃព្រហស្បតិ៍)<br>• នាទីព្រឹត្តិការណ៍ជុំវិញតំបន់ (សុក្រ)<br>• នាទីយល់ដឹងអំពីអូស្ត្រាលី (សៅរ៍)<br>• នាទីភាគពិសេសៗ (អាទិត្យ) | 06:១៧ & ១២:១៧ |
| ព័ត៌មានសង្ខេប និងបិទកម្មវិធី | 06:២៧ - 06:៣0<br>១២:២៧ - ១២:៣0 |

## នាទីឯកទេស

**នាទីកសិកម្ម និងបរិស្ថាន៖**

តាមដានបញ្ហាកសិកម្មនិងបរិស្ថាន ការរីកចំរើនខាងវិស័យនេះនៅក្នុងប្រទេស និងនៅលើសកលលោក។

**នាទីកម្រងសង្គម៖**

ផ្សាយអំពីបញ្ហាដែលទាក់ទងនឹងជីវិតរបស់យើងមានដូចជាការអប់រំប្រវត្តិសាស្ត្រ សាសនា វប្បធម៌ និងបញ្ហាផ្សេងៗព្រមទាំងដំណោះស្រាយជាដើមនៅក្នុងសង្គមខ្មែរ និងនៅក្នុងសកលលោក។

**នាទីសុខភាព៖**

តាមដាននាទីនេះដើម្បីពង្រឹងចំណេះដឹងនិងការថែទាំសុខភាពទូទៅ ។

**នាទីវិទ្យាសាស្រ្ត៖**

បច្ចេកវិទ្យានិងការស្រាវជ្រាវអាចធ្វើឲ្យមានការប៉ះពាល់ដល់ការរស់នៅរបស់យើង។ តើការវិវឌ្ឍខាងវិស័យនេះបានឈានដល់កំរិតណាហើយ?

**នាទីព្រឹត្តិការណ៍ជុំវិញតំបន់៖**

ផ្តល់ព័ត៌មានអំពីព្រឹត្តិការណ៍ដែលបានកើតឡើង ហើយនឹងអាចកើតឡើងដែលធ្វើឲ្យ តំបន់ទាំងមូលមានការចាប់អារម្មណ៍។

**នាទីយល់ដឹងអំពីអូស្ត្រាលី៖**

ជំរាបជូនអំពីព្រឹត្តិការណ៍ និងការយល់ដឹងជុំវិញអូស្ត្រាលីដែលធ្វើឲ្យតំបន់ទាំងមូល ចាប់អារម្មណ៍។

**កម្រងនាទីភាគពិសេសៗ៖**

ផ្សាយអំពីកម្រងកម្មវិធីភាគផ្សេងៗដើម្បីបំប៉នការយល់ដឹងរបស់លោកអ្នកថែម ទៀត។